ការបណ្តុះបណ្តាលដើម្បីជួយក្នុងការផ្សព្វផ្សាយក្រមរដ្ឋប្បវេណី
និង ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា លើកទី៣

# មូលដ្ឋានគ្រឹះនៃការទទួលស្គាល់អង្គហេតុ

ថ្ងៃទី14 ខែកុម្ភៈ ឆ្នាំ2014

ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវកិច្ចការច្បាប់ទូទៅ
ICD សាស្ត្រាចារ្យ Mr. Mori Tomoya

## មាតិកា

1. ចំណេះដឹងបឋម
2. ទម្រង់នៃការទទួលស្គាល់អង្គហេតុ
3. ភស្តុតាងជាឯកសារ និងសាក្សី
4. វិធីធ្វើការទទួលស្គាល់អង្គហេតុ
5. Q & A

1

# 1 ចំណេះដឹងបឋម



## 1-1 ក្តាប់នូវអង្គហេតុដែលជាកម្មវត្ថុនៃការបញ្ជាក់ភស្តុតាង

| | | | |
|---|---|---|---|
| ដំណាក់កាលនៃការទាមទារ | ការទាមទាររបស់ដើមចោទ<br>↓<br>ចម្លើយរបស់ចុងចម្លើយ | *Ex)រឿងក្តីទាមទារប្រាក់កម្ចី*<br>·ករណីទទួលស្គាល់→ការទទួលស្គាល់នូវការទាមទារ (មាត្រា221)<br>·ករណីមានវិវាទ→ធ្វើការអះអាង | សេចក្តីសម្រេចបញ្ចប់ |
| ដំណាក់កាលនៃការអះអាង | ↓<br>មូលហេតុនៃការទាមទាររបស់ដើមចោទ អង្គហេតុA, B<br>↓<br>ការទទួលស្គាល់ឬមិនទទួលស្គាល់របស់ចុងចម្លើយ | *Ex)*<br>*អង្គហេតុA:*<br>*អង្គហេតុB:*<br>·ទទួលស្គាល់អង្គហេតុA→ការសារភាព(មាត្រា123 កថាខ័ណ្ឌទី2)<br>·មិនទទួលស្គាល់អង្គហេតុB→ធ្វើការបញ្ជាក់ភស្តុតាង | រៀបចំការអះអាង |
| ដំណាក់កាលនៃការបញ្ជាក់ភស្តុតាង | អង្គហេតុB<br>↑<br>បញ្ជាក់ភស្តុតាង | | ទទួលស្គាល់អង្គហេតុ |

## 1-2 គោលការណ៍មូលដ្ឋានស្ដីពីការទទួលស្គាល់អង្គហេតុ (ទី១)

- គោលការណ៍ជំនឿទុកចិត្តដោយសេរី(មាត្រា184)
  - ឯកសារមូលដ្ឋាននៃការទទួលស្គាល់អង្គហេតុ(សូមមើល មាត្រា123 កថាខ័ណ្ឌទី1)

    ① លទ្ធផលនៃការពិនិត្យភស្តុតាង

    *Ex)*

    ② ដំណើរការ និង ខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់

    *Ex)*
  - បទដ្ឋាននៃការទទួលស្គាល់អង្គហេតុ

    ត្រូវពិចារណាឱ្យបានហ្មត់ចត់នូវចំណុច① និង② ហើយធ្វើការវិនិច្ឆ័យថា តើការអះអាងអំពីអង្គហេតុនោះ ជាការពិត ឬមិនពិត ដោយផ្អែកលើជំនឿទុកចិត្តដោយសេរីរបស់ខ្លួន។

4

## 1-3 គោលការណ៍មូលដ្ឋានស្ដីពីការទទួលស្គាល់អង្គហេតុ (ទី2)

- ការទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង

មានអង្គហេតុណាមួយ ដែលមិនដឹងថា ជាការពិត ឬមិនពិត ទោះជាតាមជំនឿទុកចិត្តដោយសេរីក៏ដោយ

→មិនអាចចាត់ទុកថា អង្គហេតុនោះមានពិត តាមផ្លូវបណ្ដឹងទេ។

→មិនអាចទទួលស្គាល់នូវកំណើតអានុភាពគតិយុត្តិដោយផ្អែកលើអត្ថិភាពនៃអង្គហេតុនោះបានទេ។

Cf. សូមមើលស្លាយដ៍នៃមេរៀនថ្ងៃទី12កុម្ភៈ

*Ex) រឿងក្ដីទាមទារឱ្យសងប្រាក់កម្ចី*

5

# 2 ទម្រង់នៃការទទួលស្គាល់អង្គហេតុ

6

---

## 2-1 ការបែងចែកអង្គហេតុ

- អង្គហេតុ
  - អង្គហេតុចំបង(អង្គហេតុចំបងដែលជាធាតុផ្សំ)

    អង្គហេតុលំអិតដែលត្រូវជាល័ក្ខខ័ណ្ឌបង្កើតអានុភាពគតិយុត្តិដូចជាការបង្កើតសិទ្ធិ ឬឱបស័គនៃសិទ្ធិ ឬរំលត់សិទ្ធិ ឬរារាំងនូវការអនុវត្តសិទ្ធិ
  - អង្គហេតុប្រយោល

    អង្គហេតុដែលអាចសន្និដ្ឋានអំពីអត្ថិភាពនៃអង្គហេតុចំបង ឬអាចរារាំងនូវការសន្និដ្ឋាននេះ
  - អង្គហេតុបន្ទាប់បន្សំ

    អង្គហេតុដែលទាក់ទិននឹងសមត្ថភាពនៃការបញ្ជាក់ភស្តុតាង (ភស្តុតាងដែលសមល្មមជាប្រយោជន៍ក្នុងការបង្កើតជំនឿទុកចិត្តរបស់ចៅក្រម)

7

## 2-1 ការបែងចែកអង្គហេតុ(ត)

- *ឧទាហរណ៍(រឿងក្តីទាមទារឱ្យសងប្រាក់កម្ចី)*
  - *អង្គហេតុចំបង(អង្គហេតុចំបងដែលជាធាតុផ្សំ)*
    ①
    ②
  - *អង្គហេតុប្រយោល*
    ①
    ②
  - *អង្គហេតុបន្ទាប់បន្សំ*

8

## 2-2 ការបែងចែកភស្តុតាង

- ភស្តុតាង
  - ភស្តុតាងផ្ទាល់
    ភស្តុតាងដើម្បីបញ្ជាក់ផ្ទាល់នូវអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុចំបង
  - ភស្តុតាងប្រយោល
    ភស្តុតាងដើម្បីបញ្ជាក់ផ្ទាល់នូវអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុប្រយោល ឬអង្គហេតុបន្ទាប់បន្សំ

9

## 2-2 ការបែងចែកភស្តុតាង(ត)

- *ឧទាហរណ៍(រឿងក្ដីទាមទារឱ្យសងប្រាក់កម្ចី)*
  - *ភស្តុតាងផ្ទាល់*
    - ①
    - ②
  - *ភស្តុតាងប្រយោល*
    - ①
    - ②

10

## 2-3 ទម្រង់នៃការទទួលស្គាល់អង្គហេតុ

- ប្រភេទភស្តុតាងផ្ទាល់




- ប្រភេទដែលអាចសន្និដ្ឋានអំពីអង្គហេតុប្រយោល




11

# 3 ភស្តុតាងជាឯកសារ និង សាក្សី

12

## 3-1 ការបែងចែកភស្តុតាងជាឯកសារ

- ភស្តុតាងជាឯកសារពាក់ព័ន្ធនឹងការចាត់ចែង
  - ឯកសារដែលមានសរសេរអំពីសកម្មភាពគតិយុត្តិបង្ហាញឆន្ទៈ ជាអាទិ៍
    *Ex) កិច្ចសន្យា, លិខិតជូនដំណឹងរំលាយកិច្ចសន្យា*
  - អ្នកដែលបានបង្កើតឯកសារនោះ បានបង្ហាញឆន្ទៈផ្ទាល់អំពីការធ្វើសកម្មភាពគតិយុត្តិកំណត់មួយ ហេតុនេះហើយ អាចធ្វើការទទួលស្គាល់ដោយផ្ទាល់នូវអង្គហេតុចំបងនៃការបង្កើតកិច្ចសន្យា ជាអាទិ៍។
    →គេចាត់ទុកថា នេះគឺជាភស្តុតាងសំខាន់ខ្លាំងណាស់។
  - ប្រសិនជាមានការបង្ហាញឆន្ទៈរបស់អ្នកបង្កើត
    →ភស្តុតាងនៃសុក្រិតភាពនៃការបង្កើតឯកសារ គឺសំខាន់ណាស់

13

## 3-1 ការបែងចែកភស្តុតាងជាឯកសារ(ត)

- ឯកសារពាក់ព័ន្ធនឹងការចាត់ចែង និង ចំណុចដែលត្រូវប្រយ័ត្នក្នុងការទទួលស្គាល់អង្គហេតុ
  - គោលការណ៍មូលដ្ឋាន

    បើសិនជាទទួលស្គាល់ថា ឯកសារត្រូវបានបង្កើតឡើងពិតប្រាកដ ត្រូវទទួលស្គាល់នូវអង្គហេតុដែលមានសរសេរក្នុងឯកសារនោះ លើកលែងតែមានសភាពការណ៍ពិសេស។
  - ចំណុចដែលត្រូវប្រយ័ត្នក្នុងករណីដែលទទួលស្គាល់នូវអង្គហេតុដូចដែលបានសរសេរ

    ត្រូវតែពិចារណាជាប្រចាំអំពីអត្ថិភាព ឬនត្ថិភាពនៃសភាពការណ៍ពិសេសដែលធ្វើឱ្យមិនអាចទទួលស្គាល់អង្គហេតុដូចដែលបានសរសេរ។
  - ចំណុចដែលត្រូវប្រយ័ត្នក្នុងករណីដែលទទួលស្គាល់នូវអង្គហេតុផ្ទុយនឹងខ្លឹមសារដែលបានសរសេរ

    មិនអនុញ្ញាតឱ្យធ្វើការទទួលស្គាល់នូវអង្គហេតុដែលផ្ទុយនឹងខ្លឹមសារនៃឯកសារ ដោយមិនបង្ហាញច្បាស់លាស់អំពីសភាពការណ៍ពិសេសគ្រប់គ្រាន់ដើម្បីបដិសេធនូវឯកសារជាភស្តុតាងនោះឡើយ។

14

## 3-1 ការបែងចែកភស្តុតាងជាឯកសារ(ត)

- ឯកសាររបាយការណ៍
  - ឯកសារសរសេរអំពីអ្វីៗដែលអ្នកបង្កើតឯកសារបានមើលឃើញ បានឮ ឬអំពីចំណាប់អារម្មណ៍ ឬអំពីការវិនិច្ឆ័យ ឬអំពីការចងចាំ ជាអាទិ៍

    *Ex) វិក័យប័ត្រ, កំណត់ប្រចាំថ្ងៃ, បញ្ជី, កំណត់, លិខិតថ្លែងការណ៍*

  - បានទទួលស្គាល់នូវសុក្រិតភាពនៃការបង្កើតភស្តុតាងជាឯកសារ

→ការយល់ដឹង មតិ ឬការវិនិច្ឆ័យរបស់អ្នកបង្កើត នៅពេលធ្វើឯកសារនោះ ត្រូវបានកំណត់ជាស្ថាពរ

*Ex) ការចុះបញ្ជីគណនេយ្យពាណិជ្ជកម្ម*

15

# 3-1 ការបែងចែកភស្តុតាងជាឯកសារ(ត)

- ឯកសាររបាយការណ៍ និង ចំណុចដែលត្រូវប្រយ័ត្នក្នុងការទទួលស្គាល់អង្គហេតុ
  - សមត្ថភាពបញ្ជាក់ភស្តុតាង (ភស្តុតាងសមល្មមជាប្រយោជន៍ក្នុងការបង្កើតជំនឿទុកចិត្តរបស់ចៅក្រម) ផ្សេងៗគ្នា ទៅតាមលក្ខណៈនៃឯកសារ។
  - ឯកសារដែលត្រូវបានចាត់ទុកថា មានសមត្ថភាពខ្ពស់ក្នុងការបញ្ជាក់ភស្តុតាង ដោយពិចារណាដល់អ្នកបង្កើត ពេលវេលាបង្កើត ខ្លឹមសារនៃឯកសារ មានដូចតទៅ
    - ឯកសារធ្វើឡើងដោយអ្នកដែលគ្មានពាក់ព័ន្ធនឹងផលប្រយោជន៍
    - ឯកសារដែលបានធ្វើឡើងនៅពេលជិតនឹងពេលនៃអង្គហេតុដែលជាកម្មវត្ថុនៃការបញ្ជាក់ភស្តុតាង
    - ឯកសារដែលមានខ្លឹមសារធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់អ្នកធ្វើឯកសារនោះ

    *Ex) វិក័យប័ត្រ, បង្កាន់ដៃបញ្ជាក់ការទទួល, លិខិតផ្សេងៗ*

16

# 3-2 សាក្សី

- លក្ខណៈពិសេសនៃសាក្សី
  - ចាំបាច់ត្រូវដឹងទាំងស្រុងអំពីរឿងទាំងមូល បើមិនដូច្នេះទេ មិនអាចធ្វើការទទួលស្គាល់អង្គហេតុបានឡើយ។
  - អាចមានការប្រែប្រួលខ្លាំងទៅតាមវិធីសាកសួរសាក្សី បើសិនជាមិនបានកំណត់ឱ្យបានច្បាស់លាស់នូវខ្លឹមសារ។
  - សេចក្តីថ្លែងការណ៍របស់សាក្សី អាចមានកំហុស។
    - ថ្លែងការណ៍មិនពិតដោយចេតនា។
    - ពិនិត្យពិចារណាមិនគ្រប់គ្រាន់។
    - ការចងចាំមានការប្រែប្រួល។
    - មានបញ្ហា ឬកង្វះសមត្ថភាពខាងប្រើពាក្យសំដី ។
    - យល់ច្រឡំចំពោះន័យនៃសំណួរ។

17

# 4 វិធីធ្វើការទទួលស្គាល់អង្គហេតុ

18

## 4-1 ទម្រង់នៃការទទួលស្គាល់អង្គហេតុ

(លើកឡើងម្តងទៀត)

- ប្រភេទភស្តុតាងផ្ទាល់




- ប្រភេទដែលអាចសន្និដ្ឋានអំពីអង្គហេតុប្រយោល




19

## 4-2 ប្រភេទភស្តុតាងផ្ទាល់

- លក្ខណៈពិសេសនៃប្រភេទភស្តុតាងផ្ទាល់
  - ពុំមានដំណាក់កាលណាមួយដើម្បីធ្វើការសន្និដ្ឋានអង្គហេតុ ពីអង្គហេតុប្រយោលទេ។

  ≠ កម្រិតនៃការបង្កើតជំនឿទុកចិត្តដោយអង្គហេតុផ្ទាល់ មានខ្ពស់ជាងកម្រិតនៃការបង្កើតជំនឿទុកចិត្តដោយអង្គហេតុប្រយោល។
    - ភស្តុតាងផ្ទាល់ មានតាំងពីឯកសារពាក់ព័ន្ធនឹងការចាត់ចែងរហូតដល់ឯកសារថ្លែងការណ៍។
  - ទោះជាករណីដែលមានឯកសារពាក់ព័ន្ធនឹងការចាត់ចែងក៏ដោយ ក៏ចាំបាច់ត្រូវធ្វើការត្រួតពិនិត្យនូវភាពសមហេតុសមផល ឬជំនឿទុកចិត្ត តាមរយៈអង្គហេតុបន្ទាប់បន្សំផងដែរ។

  ~នៅក្នុងដំណាក់កាលនៃការវិនិច្ឆ័យនោះ ត្រូវឆ្លងកាត់តាមដំណាក់កាលវិនិច្ឆ័យប្រហាក់ប្រហែលគ្នានឹងការសន្និដ្ឋានអង្គហេតុចំបង ពីអង្គហេតុប្រយោលដែរ។

20

## 4-2 ប្រភេទភស្តុតាងផ្ទាល់(ត)

- ចំណុចដែលត្រូវប្រយ័ត្នពាក់ព័ន្ធនឹងបញ្ហាមាន ឬគ្មានភស្តុតាងផ្ទាល់
  - ករណីដែលមានលិខិតកិច្ចសន្យា ឬវិក័យប័ត្រ ជាអាទិ៍ ដែលត្រូវបានបង្កើតឡើងពិតប្រាកដ

  →ត្រូវទទួលស្គាល់នូវអង្គហេតុដែលមានសរសេរក្នុងឯកសារនោះ លើកលែងតែមានសភាពការណ៍ពិសេស។ Cf. ស្លាយដ៏ទី14
  - ក្នុងករណីដែលគ្មានភស្តុតាងផ្ទាល់ ដែលតាមធម្មតា គេតែងតែធ្វើនោះ (*Ex. លិខិតកិច្ចសន្យាលក់ទិញវត្ថុតម្លៃខ្ពស់*)

  →ការគ្មានធ្វើលិខិតនោះ គឺជាអង្គហេតុប្រយោលដ៏សំខាន់។

21

## 4-3 ប្រភេទដែលអាចសន្និដ្ឋានពីអង្គហេតុប្រយោល

- ចំណុចដែលត្រូវប្រយ័ត្នក្នុងការទទួលស្គាល់អង្គហេតុ
  - ត្រូវគិតជាប្រចាំថា មានដំណាក់កាលពីរដូចខាងក្រោមនេះ ៖
    - ការទទួលស្គាល់អង្គហេតុប្រយោលដោយភស្តុតាងប្រយោល
    - ការសន្និដ្ឋានអង្គហេតុចំបង ពីអង្គហេតុប្រយោល
  - ការសន្និដ្ឋានពីអង្គហេតុប្រយោល ទៅអង្គហេតុចំបង ត្រូវធ្វើទៅតាមបទពិសោធន៍។

→តាមធម្មតា បទពិសោធន៍តែងតែមានករណីពិសេស។ ចាំបាច់ត្រូវពិចារណាឱ្យបានហ្មត់ចត់ថា តើមានសភាពការណ៍អ្វីដែលអាចរារាំងនូវការទទួលស្គាល់អង្គហេតុនោះដែរឬទេ?

22

## 4-4 ការអនុវត្តជាក់ស្តែងក្នុងការជំនុំជម្រះរឿងក្តីរដ្ឋប្បវេណី

1 ត្រូវរិះរកអង្គហេតុចំបងដែលចាំបាច់ដើម្បីធ្វើការកំណត់ជាស្ថាពរថា តើអង្គហេតុចំបងដែលជាបញ្ហានោះ មានដែរឬទេ។

2A ករណីដែលគ្មានភស្តុតាងផ្ទាល់ (ដែលអាចជឿជាក់បាន)

- ធ្វើការវិនិច្ឆ័យថា តើអាចធ្វើការសន្និដ្ឋានអំពីអង្គហេតុចំបង ពីអង្គហេតុប្រយោលនៃ1បានដែរឬទេ

2B ករណីដែលមានភស្តុតាងផ្ទាល់ (ដែលអាចជឿជាក់បាន)

- ភស្តុតាងផ្ទាល់ដែលត្រូវនឹង ឬស្របនឹង ឬមិនផ្ទុយនឹងអង្គហេតុនៃ1 ត្រូវចាត់ទុកថា អាចជឿជាក់បាន។
- ភស្តុតាងផ្ទាល់ដែលផ្ទុយនឹងអង្គហេតុប្រយោលនៃ1 មិនអាចជឿបានទេ។

23

## 5 Q & A



# Thank you.